# សៀវភៅមគ្គុទេសក៍

## ដំណើរការស្នើសុំសេវាសាធារណៈឌីជីថល

## របស់និយ័តករទូរគមនាគមន៍កម្ពុជា

(ជំនាន់ ១.០)

២០២៤

# មាតិកា


១. សេចក្តីណែនាំ ..... ៣

២. ការចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធ ..... ៤

២.១ ការចូលទៅកាន់គេហទំព័ររបស់ប្រព័ន្ធ ..... ៤

២.២ ទំព័រដើមរបស់ប្រព័ន្ធ ..... ៤

២.៣ FAQ ..... ៤

២.៤ ប្តូរភាសា ..... ៤

២.៥ ចូលប្រើប្រាស់ប្រព័ន្ធ ..... ៥

៣. ផ្ទាំងគ្រប់គ្រង ..... ៦

៣.១ របារចំហៀង (Sidebar) ..... ៦

៣.២ ក្រុមហ៊ុន ..... ៧

៣.៣ បុគ្គលិកក្រុមហ៊ុន ..... ៩

៣.៤ ពាក្យស្នើសុំទាំងអស់ ..... ១១

៣.៥ ស្នើសុំទៅសេវាណាមួយ ..... ១២

៣.៦ មើលព័ត៌មានពាក្យស្នើសុំ ..... ១៧

៣.៧ ស្នើសំណើរឡើងវិញក្រោយធ្វើការបដិសេធ ..... ១៨

៣.៨ បង់ថ្លៃពាក្យស្នើសុំ ..... ២០

៣.៩ បង់ថ្លៃពាក្យលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រ ..... ២១

៣.១០ ទាញយកលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រ ..... ២២

៤. ជំនួយបន្ថែម ..... ២៣

## ១. សេចក្តីណែនាំ

ប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថល បង្កើតឡើងដើម្បីគាំទ្រសេវាកម្មសាធារណៈដែលអ្នកប្រើប្រាស់អាចស្នើរសុំ និងតាមដានដំណើរការឯកសារលើគេហទំព័រនេះបាន ហើយក្រុមការងារ ន.ទ.ក. អាចដំណើរការឯកសារតាមប្រព័ន្ធអ៊ីនធឺណិត។ អតិថិជន ឬអ្នកប្រើប្រាស់អាចបង់ថ្លៃសេវាតាមប្រព័ន្ធនេះ ហើយពុំមាននៅបញ្ជរបង់ប្រាក់ទៀតទេ។ ប្រព័ន្ធនេះទទួលនូវវិធីសាស្រ្តទូទាត់ដូចជា ABA KHQR ឬ CREDIT CARD / DEBIT CARD ដូចជា VISA CARD, MASTER CARD, UNION PAY, JCB ។

ក្នុងប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថលនេះ អ្នកប្រើប្រាស់អាចស្នើសុំបាននូវ ៦ សេវាធំៗដូចជា៖

- ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍។
- ស្នើសុំលិខិតអនុញ្ញាតការនាំចូល គ្រឿងសម្ភារបរិក្ខារវិទ្យុទូរគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍។
- ស្នើសុំលិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន។
- ស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍។
- ស្នើសុំលិខិតអនុញ្ញាតថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍។
- ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់នឹងចែកចាយគ្រឿងសម្ភារបរិក្ខារ វិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍។

# ២. ការចាប់ផ្ដើមប្រើប្រាស់ប្រព័ន្ធ

## ២.១ ការចូលទៅកាន់គេហទំព័ររបស់ប្រព័ន្ធ

ដើម្បីចូលទៅកាន់ប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថល សូមវាយ **www.service.trc.gov.kh** ទៅកាន់កម្មវិធីស្វែងរក។

## ២.២ ទំព័រដើមរបស់ប្រព័ន្ធ




## ២.៣ FAQ

សំណួរដែលសួរញឹកញាប់ (FAQ) នៅលើគេហទំព័រគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្តល់ចម្លើយរហ័សចំពោះសំណួរទូទៅដែលអ្នកប្រើប្រាស់អាចមាន។




## ២.៤ ប្តូរភាសានៅលើប្រព័ន្ធ

ដើម្បីប្តូរភាសានៅលើប្រព័ន្ធ អតិថិជនត្រូវចុចលើរូបទង់ជាតិ នៅក្នុង Header Bar។



## ២.៥ ចូលប្រើប្រាស់ប្រព័ន្ធដោយប្រើ CamDigiKey

ដើម្បីចូលប្រើប្រាស់ប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថល អតិថិជនត្រូវមាន គណនី CamDigiKeyនៅក្នុងទូរស័ព្ទដៃឆ្លាតវៃជាមុនសិន។ ដើម្បីដឹងពីរបៀបណែនាំក្នុងការបង្កើត គណនី CamDigiKey សូមចូលទៅកាន់គេហទំព័រ **www.camdigikey.gov.kh**។

ក្រោយបង្កើត គណនី CamDigiKey ជោគជ័យ អតិថិជនអាចចូលទៅក្នុង ប្រព័ន្ធចុះបញ្ជីអេឡិកត្រូនិក ដោយចុចទៅលើប៊ូតុង “ ចូលប្រើប្រាស់ជាមួយ CamDigiKey ” ក្នុងទំព័រដើម។






បើកកម្មវិធី CamDigiKey នៅក្នុងទូរស័ព្ទដៃរបស់អ្នកប្រើប្រាស់ រួចធ្វើការស្កេន QR Code ខាងលើ ។ ប្រព័ន្ធនឹងធ្វើការ Redirect មកកាន់ **ផ្ទាំងគ្រប់គ្រង** ។




## ៣. ផ្ទាំងគ្រប់គ្រង ( Dashboard )




### ៣.១ របារចំហៀង ( Sidebar )



របារចំហៀងប្រើសម្រាប់ផ្ទុកទំព័រស្វែងរកដូចជា ពាក្យស្នើសុំទាំងអស់ ក្រុមហ៊ុន និងបុគ្គលិកក្រុមហ៊ុន។ ដើម្បីបើកឬបិទរបារចំហៀងអតិថិជនត្រូវចុចលើ ប៊ូតុងសញ្ញាព្រួញដែលបាន Mark លើរូប។



## ៣.២ ក្រុមហ៊ុន




គ្រប់គ្រង ឬបង្កើតក្រុមហ៊ុនរបស់អតិថិជនសម្រាប់ស្នើសុំសេវានីមួយៗ ពីប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថលដោយចូលទៅកាន់ របារចំហៀង រួចចុចទៅលើ ប៊ូតុង “ ក្រុមហ៊ុន ” នោះប្រព័ន្ធនិងនាំមកនូវ ទំព័រគ្រប់គ្រងក្រុមហ៊ុន។




| ល.រ | ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ឈ្មោះក្រុមហ៊ុនជាភាសាឡាតាំង | លេខទូរស័ព្ទ | អ៊ីម៉ែល | អាសយដ្ឋាន | សកម្មភាព |
|---|---|---|---|---|---|---|
| 1 | អិម អាយ អេស ខេមបូឌា | MIS Cambodia | 093752006 | rothsron@gmail.com | រាជធានីភ្នំពេញ, ច្បារអំពៅ, ព្រែកឯង , តាព្រហ្ម , Street N1 , HouseNo Q16 | កែប្រែ |
| 2 | ABC Company CO, LTD | ABC Company CO, LTD | 087799949 | sovandykh168@gmail.com | បន្ទាយមានជ័យ, អូរជ្រៅ, កូប , ម៉ក់ហឺន , Street 116 , HouseNo 74C | កែប្រែ |
| 3 | ABC | ABC | 087799949 | sovandykh168@gmail.com | ព្រះសីហនុ, ស្ទឹងហាវ, ទំនប់រលក , ភូមិ២ , Street 114 , HouseNo 74C | កែប្រែ |



ដើម្បីបង្កើត ក្រុមហ៊ុនថ្មីអតិថិជនអាចចុចទៅលើប៊ូតុង “ បង្កើតថ្មី ” ដែលបានគូសសម្គាល់នៅរូបខាងលើ។ បំពេញព័ត៌មានដែលប្រព័ន្ធទាមទារ រួចចុចប៊ូតុង “ រក្សាទុក ” ។



អ្នកប្រើប្រាស់និងទទួលបាន ក្រុមហ៊ុនថ្មីនៅក្នុងតារាងគ្រប់គ្រងក្រោយបង្កើតបានជោគជ័យ។




ដើម្បីកែប្រែទិន្នន័យក្រុមហ៊ុនរបស់អ្នកប្រើប្រាស់ សូមចុចប៊ូតុង " កែប្រែ " ដែលនៅជួរដេករួមគ្នាជាមួយនិងក្រុមហ៊ុនដែលអ្នកប្រើប្រាស់ចង់ធ្វើការកែប្រែ។







បំពេញព័ត៌មានដែលត្រឹមត្រូវ រួចចុចប៊ូតុង " កែប្រែ " ប្រព័ន្ធនិងកែប្រែព័ត៌មានដែលត្រឹមត្រូវទៅទិន្នន័យក្រុមហ៊ុននោះ។

## ៣.៣ បុគ្គលិកក្រុមហ៊ុន

គ្រប់គ្រង ឬបង្កើតបុគ្គលិករបស់អតិថិជនសម្រាប់ស្នើសុំសេវានីមួយៗ ពីប្រព័ន្ធស្នើសុំសេវាសាធារណៈឌីជីថលដោយចូលទៅកាន់ របារចំហៀង រួចចុចទៅលើ ប៊ូតុង “ បុគ្គលិកក្រុមហ៊ុន ” នោះប្រព័ន្ធនិងនាំមកនូវ ទំព័រគ្រប់គ្រងបុគ្គលិកក្រុមហ៊ុន។






គ្រប់គ្រងបុគ្គលិក

បុគ្គលិកទាំងអស់ បង្កើតថ្មី

Show 10 entries Search:

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាភាសាឡាតាំង | ភេទ | មុខតំណែង | ប្រភេទអត្តសញ្ញាណ | លេខអត្តសញ្ញាណ | លេខទូរស័ព្ទ | អ៊ីមែល | សកម្មភាព |
|---|---|---|---|---|---|---|---|---|---|
| 1 | ស្រ៊ន រដ្ឋ | SRON ROTH | ប្រុស / Male | IT | អត្តសញ្ញាណប័ណ្ណសញ្ជាតិ / Nationality IDCard | 01919191881 | 093752006 | rothsron@gmail.com | កែប្រែ |
| 2 | ខ្ញី សុវណ្ណឌី | KHGNEY SOVANDY | ប្រុស / Male | Developer | អត្តសញ្ញាណប័ណ្ណសញ្ជាតិ / Nationality IDCard | 21564584654564 | 087799949 | sovandykh168@gmail.com | កែប្រែ |
| 3 | Sovandy | Sovandy | ប្រុស / Male | Dev | អត្តសញ្ញាណប័ណ្ណសញ្ជាតិ / Nationality IDCard | 001 | 098799949 | sovandykh168@gmail.com | កែប្រែ |

Previous Next

ដើម្បីបង្កើត បុគ្គលិកក្រុមហ៊ុនថ្មី អតិថិជនអាចចុចទៅលើប៊ូតុង “ បង្កើតថ្មី ” ដែលបានគូសសម្គាល់ នៅរូបខាងលើ។ បំពេញព័ត៌មានដែលប្រព័ន្ធទាមទារ រួចចុចប៊ូតុង “ រក្សាទុក ” ។



អ្នកប្រើប្រាស់និងទទួលបាន បុគ្គលិកក្រុមហ៊ុនថ្មីនៅក្នុងតារាងគ្រប់គ្រងក្រោយបង្កើតបានជោគជ័យ។







ដើម្បីកែប្រែទិន្នន័យបុគ្គលិកក្រុមហ៊ុនរបស់អ្នកប្រើប្រាស់ សូមចុចប៊ូតុង “ កែប្រែ ” ដែលនៅជួរដេករួមគ្នាជាមួយនិងទិន្នន័យដែលអ្នកប្រើប្រាស់ចង់ធ្វើការកែប្រែ។




បំពេញព័ត៌មានដែលត្រឹមត្រូវ រួចចុចប៊ូតុង “ កែប្រែ ” ប្រព័ន្ធនិងកែប្រែព័ត៌មានដែលត្រឹមត្រូវទៅទិន្នន័យបុគ្គលិកក្រុមហ៊ុននោះ។

## ៣.៤ ទំព័រពាក្យស្នើសុំទាំងអស់

### ទម្រង់បែបបទក្នុងការស្នើសុំ

១. ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

ស្នើសុំទៅទម្រង់នេះ

**ពាក្យស្នើសុំទាំងអស់**

Show 10 entries Search:

| ល.រ | លេខសម្គាល់ពាក្យស្នើសុំ | ឈ្មោះអ្នកស្នើសុំ | ក្រុមហ៊ុនអតិថិជន | ប្រធានបទ | កាលបរិច្ឆេទស្នើសុំ | ស្ថានភាពបច្ចុប្បន្ន | មតិយោបល់ | ស្ថានភាពអនុម័ត | សកម្មភាព |
|---|---|---|---|---|---|---|---|---|---|
| 1 | TL-TA-2024-0005 | ខ្ញី សុវណ្ណឌី | ABC Company CO, LTD | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 17/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |
| 2 | TL-TA-2024-0004 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Receive Document | Customer Payment On Certificate | បានអនុម័ត | Action |
| 3 | TL-TA-2024-0003 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Payment Submit | Received Customer Payment | កំពុងពិនិត្យ | Action |
| 4 | TL-TA-2024-0002 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |
| 5 | RC-TA-2024-0001 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ក. វិទ្យុគមនាគមន៍<br>A. Radiocommunication Equipment | 11/Jan/2024 | Customer Receive Document | Customer Payment On Certificate | បានអនុម័ត | Action |
| 6 | TL-TA-2024-0001 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |

Previous Next

ទំព័រពាក្យស្នើសុំទាំងអស់ ផ្ទុករាល់សំណើរបស់សេវាទាំង៦ ដែលអ្នកប្រើប្រាស់ស្នើសុំមកកាន់ប្រព័ន្ធអេឡិកត្រូនិក។ ទំព័រនេះមានសមាសធាតុ (Components) ៣ សំខាន់គឺ។

ក. Dropdown សម្រាប់ផ្លាស់ប្តូរប្រភេទសេវាសាធារណៈ

១. ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

១. ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
២. ស្នើសុំលិខិតអនុញ្ញាតការនាំចូល គ្រឿងសម្ភារបរិក្ខារវិទ្យុទូរគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍
៣. ស្នើសុំលិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន
៤. ស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លីទូរគមនាគមន៍
៥. ស្នើសុំលិខិតអនុញ្ញាតថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លីទូរគមនាគមន៍
៦. ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់និងចែកចាយគ្រឿងសម្ភារបរិក្ខារ វិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

ខ. ប៊ូតុងសម្រាប់ស្នើសុំទៅសេវានោះ: ស្នើសុំទៅទម្រង់នេះ

គ. តារាងគ្រប់គ្រងសំណើទាំង ៦ សេវាដែលអ្នកប្រើប្រាស់ធ្លាប់ស្នើសុំរួច

**ពាក្យស្នើសុំទាំងអស់**

Show 10 entries Search:

| ល.រ | លេខសម្គាល់ពាក្យស្នើសុំ | ឈ្មោះអ្នកស្នើសុំ | ក្រុមហ៊ុនអតិថិជន | ប្រធានបទ | កាលបរិច្ឆេទស្នើសុំ | ស្ថានភាពបច្ចុប្បន្ន | មតិយោបល់ | ស្ថានភាពអនុម័ត | សកម្មភាព |
|---|---|---|---|---|---|---|---|---|---|
| 1 | TL-TA-2024-0005 | ខ្ញី សុវណ្ណឌី | ABC Company CO, LTD | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 17/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |
| 2 | TL-TA-2024-0004 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Receive Document | Customer Payment On Certificate | បានអនុម័ត | Action |
| 3 | TL-TA-2024-0003 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Payment Submit | Received Customer Payment | កំពុងពិនិត្យ | Action |
| 4 | TL-TA-2024-0002 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |
| 5 | RC-TA-2024-0001 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ក. វិទ្យុគមនាគមន៍<br>A. Radiocommunication Equipment | 11/Jan/2024 | Customer Receive Document | Customer Payment On Certificate | បានអនុម័ត | Action |
| 6 | TL-TA-2024-0001 | ស្រ៊ន រដ្ឋ | អិម អាយ អេស ខេមបូឌា | ខ. ទូរគមនាគមន៍<br>B. Telecommunications Equipment | 11/Jan/2024 | Customer Submit | Submit Form | កំពុងពិនិត្យ | Action |

Previous Next

### ៣.៥ ស្នើសុំទៅសេវា

ដើម្បីស្នើសុំទៅសេវាណាមួយ សូមជ្រើសរើសយកសេវាដែលអ្នកប្រើប្រាស់ចង់ស្នើនៅក្នុងបញ្ជី Dropdown ក្នុងទំព័រ ពាក្យស្នើសុំទាំងអស់ រួចចុចប៊ូតុង "ស្នើសុំទៅទម្រង់នេះ"។




ក្នុងឧទាហរណ៍នេះ យើងជ្រើសរើសសេវាទី២ " ស្នើសុំលិខិតអនុញ្ញាតការនាំចូល គ្រឿងសម្ភារបរិក្ខារវិទ្យុទូរគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ "។ បំពេញព័ត៌មានដែលចាំបាច់និងត្រូវការអោយបានត្រឹមត្រូវ។



ជ្រើសរើសអ្នកស្នើសុំ និងព័ត៌មានក្រុមហ៊ុនដែលបានបង្កើតនៅចំណុចទី ៣.២ និង ៣.៣។ (អតិថិជនអាចបំពេញ ព័ត៌មានទាំងនោះបាន បើសិនជាមិនទាន់បានបង្កើតពីមុនមក)







ពិនិត្យពាក្យស្នើសុំឡើងវិញដោយធានាថាព័ត៌មានទាំងអស់ដែលបានបញ្ចូលគឺត្រឹមត្រូវ។ រួចចុចប៊ូតុង បន្ទាប់។

បន្ទាប់មកធ្វើការភ្ជាប់ឯកសារតម្រូវការទៅនិងពាក្យស្នើសុំ។ យើងទទួលឯកសារជា File រូបភាពមានដូចជា (.jpg, .png) និង File PDF ដែលមានទំហំផ្ទុកតូចជាង ៥ មេកាបៃ (5MB)។







ពិនិត្យឯកសារភ្ជាប់អោយបានត្រឹមត្រូវរួច ចុចប៊ូតុង បញ្ជូន។

ក្រោយបញ្ជូនពាក្យស្នើសុំទៅកាន់ ន.ទ.ក. រួចមក។ ពាក្យស្នើសុំនិងរក្សាទុកនៅក្នុង តារាងគ្រប់គ្រងពាក្យស្នើសុំ។




អតិថិជនអាចតាមដានសំណើរបស់ខ្លួនដោយមើលនៅក្នុងស្ថានភាពបច្ចុប្បន្ន មតិយោបល់ និង ស្ថានភាពអនុម័ត នៅក្នុងតារាងគ្រប់គ្រងពាក្យស្នើសុំ។




អតិថិជនក៏អាចតាមដានដំណើរការលម្អិត នៃសំណើពាក្យស្នើសុំរបស់ខ្លួនផងដែរដោយ ចុចទៅលើប៊ូតុង Action ដែលនៅជួរដេកជាមួយពាក្យស្នើសុំនោះរួច ចុចទៅលើពាក្យ ពិនិត្យប្រវត្តិពាក្យស្នើសុំ។




ព័ត៌មានលម្អិត
បង្ហាញប្រវត្តិពាក្យស្នើសុំ
1
From : Customer
To : Customer Submit
Transaction Date : 12/Jan/2024
Comment : Customer Submit
2
From : Customer Submit
To : Payment Submit
Transaction Date : 14/Jan/2024
Comment : Customer Payment
3
From : Customer Submit
To : Admin Submit Form
Transaction Date : 17/Jan/2024
Comment : SDFSDf
4
From : Admin Submit Form
To : Technical Check Submit
Transaction Date : 17/Jan/2024
Comment : DFSDFSD
5
From : Technical Check Submit
To : Technical Manager Submit
Transaction Date : 17/Jan/2024
Comment : SDFDS
6
From : Technical Manager Submit
To : TRC Member Check Submit
Transaction Date : 17/Jan/2024
Comment : SDF

## ៣.៦ មើលព័ត៌មានពាក្យស្នើសុំ




ដើម្បីមើលព័ត៌មានពាក្យស្នើសុំ អតិថិជនត្រូវ ចុចទៅលើ ប៊ូតុង Action ដែលនៅជួរដេកជាមួយជាមួយសំណើស្នើសុំនោះរួចចុចទៅលើ បង្ហាញពាក្យស្នើសុំ។







មើលឯកសារភ្ជាប់ដោយចុចទៅលើ ប៊ូតុង មើល នៅលើប្រភេទឯកសារនោះ។

## ៣.៧ ដាក់សំណើស្នើឡើងវិញ




ក្រោយបញ្ជូនពាក្យស្នើសុំទៅកាន់ ន.ទ.ក. រួចមក។ ន.ទ.ក. និងធ្វើការពិនិត្យលើពាក្យស្នើសុំនោះ បើសិនមានជាមានបញ្ហាណាមួយនៅលើពាក្យស្នើសុំនោះ ន.ទ.ក. និងធ្វើការបដិសេធសំណើនោះ បូករួមជាមួយនិងមតិយោបល់។

ដើម្បីដាក់ស្នើសំណើឡើងវិញសូមចុចទៅលើប៊ូតុង Action ដែលនៅជួរដេកជាមួយជាមួយសំណើស្នើសុំនោះរួចចុចទៅលើ ដាក់ស្នើឡើងវិញ។







ពិនិត្យ និងកែប្រែសំណើ និងកន្លែងដែលខុសរួចមកចុចប៊ូតុងបន្ទាប់។



បន្ទាប់មកធ្វើការភ្ជាប់ឯកសារតម្រូវការទៅនិងពាក្យស្នើសុំ ម្តងទៀត (ឯកសារនិងធ្វើការជំនួស)។ យើងទទួលឯកសារជា File រូបភាពមានដូចជា (.jpg, .png) និង File PDF ដែលមានទំហំផ្ទុកតូចជាង ៥ មេកាបៃ (5MB)។




បន្ទាប់មកសូមធ្វើការចុច ប៊ូតុងបញ្ជូន។

| ស្ថានភាពបច្ចុប្បន្ន | មតិយោបល់ | ស្ថានភាពអនុម័ត | សកម្មភាព |
|---|---|---|---|
| Customer Submit | ReForm Submit | កំពុងពិនិត្យ | Action |

ស្ថានភាពបច្ចុប្បន្ន មិតិយោបល់ ស្ថានភាពអនុម័ត និងធ្វើការផ្លាស់ប្តូរ។ ន.ទ.ក. និងធ្វើការពិនិត្យសំណើម្តងទៀត។

# ៣.៨ បង់ប្រាក់ពាក្យស្នើសុំ




អតិថិជនអាចបង់ប្រាក់ពាក្យស្នើសុំក្រោយធ្វើការបញ្ជូនសំណើមកកាន់ ន.ទ.ក. រួចដោយ ចូលទៅ តារាងគ្រប់គ្រងពាក្យស្នើសុំ រួចចុចទៅលើ ប៊ូតុង Action ដែលនៅជួរដេកជាមួយពាក្យស្នើសុំនោះរួច ចុចទៅលើពាក្យ បង់ថ្លៃពាក្យស្នើសុំ។ ជ្រើសរើស វិធីសាស្ត្រទូទាត់ រួចធ្វើការទូរទាត់ជាការស្រេច។












គួរបញ្ជាក់ផងដែរថា ការបង់ប្រាក់ទៅលើពាក្យស្នើសុំគឺមានតែនៅ ក្នុងសេវា “ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍” និងសេវា “ ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់និងចែកចាយគ្រឿងសម្ភារបរិក្ខារ វិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍” តែប៉ុណ្ណោះ។

## ៣.៩ បង់ប្រាក់ពាក្យវិញ្ញាបនបត្រ




អតិថិជនអាចបង់ប្រាក់វិញ្ញាបនបត្រក្រោយ ន.ទ.ក. អនុម័តពាក្យស្នើសុំរួច។ ចុចទៅលើ ប៊ូតុង Action ដែលនៅជួរដេកជាមួយពាក្យស្នើសុំនោះរួចចុចទៅលើពាក្យ បង់ថ្លៃពាក្យវិញ្ញាបនបត្រ ជ្រើសរើស វិធីសាស្ត្រទូទាត់ រួចធ្វើការទូរទាត់ជាការស្រេច។












គួរបញ្ជាក់ផងដែរថា ការបង់ប្រាក់ទៅលើពាក្យវិញ្ញាបនបត្រគឺមានតែនៅ ក្នុងសេវា “ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍” សេវា “ ស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់និងចែកចាយគ្រឿងសម្ភារបរិក្ខារ វិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍” និងសេវា “ ស្នើសុំលិខិតអនុញ្ញាតការនាំចូល គ្រឿងសម្ភារបរិក្ខារវិទ្យុទូរគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍” តែប៉ុណ្ណោះ។

### ៣.១០ ការទាញយកលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ

ដើម្បីទាញយកលិខិតអនុញ្ញាតឬ វិញ្ញាបនបត្រ អតិថិជនត្រូវ ចុចទៅលើ ប៊ូតុង Action ដែលនៅជួរដេកជាមួយជាមួយសំណើស្នើសុំនោះរួចចុចទៅលើ ទាញយកវិញ្ញាបនបត្រ ឬ ទាញយកលិខិតស្នើសុំ។ គួរបញ្ជាក់ផងដែរថា ដើម្បីទាញយកលិខិតអនុញ្ញាតឬ វិញ្ញាបនបត្រ បានលុះត្រាតែសំណើនោះត្រូវ បានអនុម័តដោយ ន.ទ.ក. ។







ក្រោយចុចប៊ូតុងទាញយករួច ឯកសារនិងធ្វើការទាញយកដោយស្វ័យប្រវត្តិ។



## ៤. ជំនួយបន្ថែម

ប្រព័ន្ធសេវាសាធារណៈឌីជីថល
ផ្លូវលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ៖ 6789 (Hotline) / (+855) 23 722 333 / (+855) 23 723 222
អ៊ីម៉ែល៖ info@trc.gov.kh
គេហទំព័រ៖ www.trc.gov.kh

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
អ៊ីម៉ែល៖ info@mptc.gov.kh